រឿងអប់រំខ្លី ស្តីពីសុវត្ថិភាពលើកម្មវិធី **ONIONSHARE**

# លោកគ្រូបែកធ្លាយ




ឪពុកជាគ្រូបង្រៀនជំនាន់មុន
គាត់ត្រូវផ្ញើវិញ្ញាសារទៅ
គណៈគ្រប់គ្រងសាលា ដើម្បី
រៀបចំការប្រឡង តាមរយៈ
អ៊ីមែល
សម័យនេះហើយនៅប្រើអ៊ីមែល
ផ្ញើឯកសារសំខាន់ទៀត !!
ប៉ុប ប៉ុប
កូនក្មេងសោះ មកធ្វើចេះដឹងរឿងចាស់ៗ
ឪបង្រៀន ៣០ឆ្នាំហើយ
ចាស់ជាងកូនឯង
ពាក្យចាស់ថា
"មិនជឿចាស់ស្រឡះដៃជេង
មិនជឿក្មេង ប្រយ័ត្នបែកធ្លាយ"
អាល់ឡូ លោកនាយក!!
ជួយពិនិត្យវិញ្ញាសាផង
ខ្ញុំផ្ញើចេញទៅហើយៗ


ក្រោយពេលប្រលង.......
ហាស....ហាហា
យី! វិញ្ញាសាឯងស្រួលពេកមែន ឬ បង្រៀនល្អ បានសិស្សបានពិន្ទុពេញៗគ្រប់គ្នាចឹង?
ហឹមឪខ្ញុំ! ជិះចង្កើរលើកខ្លួនឯង
មើលអុីមែលដែល ឪផ្ញើវិញ្ញាសារចេញបន្តិចទៅ ដឹងហើយ !
ចុម! ឪច្រលំផ្ញើទៅ មានអុីមែលកូនសិស្សមួយដែរ
ម៉េចដែរឪ ជឿនៅ? គ្រូឪបែកធ្លាយ !!


អាឡូ!!
លោកគ្រូអោយជី
លើកនេះផ្ញើវិញ្ញាសា
តាមណា?
ផ្ញើតាមតេឡេក្រាមមក
លោកគ្រូ !!!
ព្រោះវាងាយស្រួល!
ចាំមើល !!
ឪឯងដឹងតែបែកធ្លាយទៀត
ហើយមិនជឿក្មេង ធ្លាយចឹង!
សារត្រូវបានបញ្ជូនបន្តពី
លោកគ្រូ បែកធ្លាយ
វិញ្ញាណសារប្រលង
13.5 MB
12:33 PM


ក្រោយពីបែកធ្លាយវិញ្ញាសារជាលើកទីពីរ លោកនាយកសាលាបានហៅ លោកគ្រូ(គ្រូបែកធ្លាយ) ទៅស្តីបន្ទោស។
មីអូន !!! ថ្ងៃមុនប្រាប់ពុកពីអីអា SHARE SHARE នោះដែលផ្ញើឯកសារកុំអោយធ្លាយ?
អូហ៍ !!! ទីបំផុតព្រមស្តាប់ក្មេងហើយមែនពុក?
ពុកប្រើ Onionshare ទៅសុវត្ថិភាព ហើយងាយស្រួលណាស់ !!


មិនតម្រូវឲ្យដំឡើង
កម្មវិធីរញ៉េរញ៉ៃច្រើន
Onionshare
អាចផ្ញើឯកសារ
ក្នុងទំហំធំ
អាចកំណត់រយៈពេលក្នុង
ការទាញយកឯកសារ
២ខែក្រោយមក
ស៊ាំណាស់ !!!
ភ្លេចប្រើ Onionshare
ឥលូវបែកធ្លាយ
បាត់!
ដំរីដើងបួនគង់មានភ្លាត់!
ត្រូវចងចាំថា
ពេលផ្ញើឯកសារត្រូវប្រើ
Onionshare

# OnionShare ជាអ្វី?

**OnionShare** គឺជាកម្មវិធីបើកចំហកូដនិងមិនគិតថ្លៃដោយអ្នកប្រើប្រាស់អាចចែករំលែកឯកសារដោយមិនកំណត់ទំហំ បង្ហោះវេបសាយ និង ជជែកជាមួយមិត្តភ័ក្តិ ឬ ក្រុមការងារដោយមានសុវត្ថិភាព និង អនាមិកតាមរយៈការប្រើប្រាស់បណ្តាញ **Tor**។



## តើកម្មវិធីនេះដំណើរការដូចម្តេចខ្លះ?

### ១. ការចែករំលែកឯកសារ

អ្នកប្រើប្រាស់អាចចែករំលែកឯកសារដោយមិនកំណត់ទំហំ ដោយគ្រាន់តែបើកកម្មវិធី **OnionShare** រួចចុចលើប៊ូតុង **Share files** បន្ទាប់មកចាប់ទាញឯកសារ ឬក៏ថតឯកសារចូលក្នុងប្រអប់ចែករំលែកឯកសារ និងចុចប៊ូតុង **Start Sharing** ដើម្បីចាប់ផ្តើមចែករំលែក។ អ្នកប្រើប្រាស់ផ្ញើតំណភ្ជាប់ និងកូនសោសម្ងាត់ទៅឱ្យភាគីម្ខាងទៀត។ ភាគីអ្នកទទួលយកតំណភ្ជាប់ទៅបើកលើកម្មវិធីរុករក **Tor** ហើយបញ្ចូលកូនសោសម្ងាត់ដើម្បីទាញយកឯកសារ។ បន្ទាប់ពីភាគីអ្នកទទួលបញ្ចប់ការទាញយកឯកសារ នោះ **OnionShare** នឹងបញ្ឈប់ម៉ាស៊ីនមេដោយស្វ័យប្រវត្តិ។

**ដំណើរការនៃការចែករំលែកឯកសារ**



# ២. បង្កើតបន្ទប់ជជែក

អ្នកប្រើប្រាស់បង្កើតបន្ទប់ឆែតឯកជន និងសុវត្ថិភាព ដោយវាមិនរក្សាទុកអ្វីទាំងអស់។ អ្នកគ្រាន់តែបើកកម្មវិធី **OnionShare** រួចចុចប៊ូតុងឆែត បន្ទាប់មកចុចចាប់ផ្តើមម៉ាស៊ីនឆែតដើម្បីដំណើរការម៉ាស៊ីនមេ។



បន្ទាប់មក អ្នកប្រើប្រាស់ផ្ញើតំណភ្ជាប់ និង កូនសោសម្ងាត់ទៅកាន់មនុស្សដែលពួកគេចង់ឱ្យចូលរួមបន្ទប់ឆែត ហើយភាគីម្ខាងទៀតយកតំណភ្ជាប់ដាក់បញ្ចូលក្នុងកម្មវិធីរុករក**Tor** រួចបញ្ចូលកូនសោសម្ងាត់ ដើម្បីចាប់ផ្តើមជជែកគ្នាដោយអនាមិក។

## ដំណើរការនៃការបង្កើតបន្ទប់ជជែក



# ៣. បង្ហោះវេបសាយ (Hosting Website)

អ្នកប្រើប្រាស់បើកកម្មវិធី **OnionShare** រួចចុចប៊ូតុង **Host a Website** បន្ទាប់មកផ្ទុកឡើងឯកសារវេបសាយទៅក្នុង **OnionShare** និង ចុចប៊ូតុងចែករំលែក។ អ្នកប្រើប្រាស់ផ្ញើតំណភ្ជាប់ទៅកាន់មនុស្សផ្សេងទៀត ហើយភាគីម្ខាងទៀតយកតំណភ្ជាប់នោះបើកលើកម្មវិធីរុករក **Tor** ដើម្បីចាប់ផ្ដើមបើកមើលវេបសាយនោះ។




## ដំណើរការនៃការបង្ហោះវេបសាយ (Hosting Website)




# តើហេតុអ្វីបានជាអ្នកគួរប្រើកម្មវិធីនេះ?

១. ចែករំលែកឯកសារដោយមានសុវត្ថិភាព
២. បង្ហោះវេបសាយដោយមិនគិតថ្លៃ និងចូលប្រើតាមរយៈកម្មវិធីរុករក **Tor**
៣. ជជែកជាមួយមិត្តភក្តិ និងក្រុមការងារដោយមានសុវត្ថិភាព ដោយមិនចាំបាច់បង្កើតគណនី
៤. កម្មវិធីនេះដំណើរការលើ **Window, MacOS** និង **Linux**

ទាញយកកម្មវិធី នៅទីនេះ